**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អគ្គលេខាធិការដ្ឋាន**
លេខ:០១៨/០៩ កហ.កកចយ

*រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៩*

# កំណត់ហេតុ ស្តីពីកិច្ចប្រជុំក្រុមការងារជាន់ខ្ពស់តុលាការគំរូ នៅសណ្ឋាគារអាំងទែរ-កុងទីណង់តាល់

ឆ្នាំពីរពាន់ប្រាំបួន ខែ ឧសភា ថ្ងៃទី ម្ភៃប្រាំ វេលាម៉ោងបី និងសាមសិបនាទីគត់ នៅសណ្ឋាគារអាំងទែរកុងទីណុងតាល់ មានរៀបចំប្រជុំក្រុមការងារជាន់ខ្ពស់តុលាការគំរូ ក្រោមអធិបតីភាពរបស់ឯកឧត្តម ស៊ុយ ម៉ុងលាង អគ្គលេខាធិការ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីពិនិត្យពិភាក្សា ។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម ស៊ុយ ម៉ុងលាង បានថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រី អ្នកនាងកញ្ញា ដែលជាតំណាងក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ និងសមាជិក សមាជិកា ដែលបានអញ្ជើញចូល រួមប្រជុំក្រុមការងារជាន់ខ្ពស់តុលាការគំរូក្នុងថ្ងៃនោះ។ ឯកឧត្តមបានជម្រាបជូនអង្គប្រជុំអំពីការផ្លាស់ប្តូររចនាសម្ព័ន្ធ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលកាលពីមុនមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ និង អង្គភាព គ្រប់គ្រងគម្រោង ប៉ុន្តែពេលនេះគឺមានតែអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌មួយប៉ុណ្ណោះ ដែលមានឯកឧត្តមផ្ទាល់ជាអគ្គលេខាធិការ បន្ទាប់ពីមានការអនុម័តលើការបង្កើតអគ្គលេខា- ធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ រួចមក ។

លោក គង់ ផល្លៈ អនុប្រធានផ្នែកគម្រោងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានធ្វើបទបង្ហាញពី ផែនការយុទ្ធសាស្ត្រតុលាការគំរូទាំងបួន តាមរយៈស្លាយដែលបានចែកជូនក្នុងអង្គប្រជុំ ។ នៅក្នុងស្លាយនោះលោកបាន ពន្យល់បង្ហាញពីចំណុចសំខាន់ៗដូចខាងក្រោម ៖

- ប្រវត្តិគម្រោងតុលាការគំរូកម្ពុជា
- ដំណាក់កាលនៃការអនុវត្តគម្រោងតុលាការគំរូ

- ភាពជឿនលឿននៃការអនុវត្តគម្រោងតុលាការគំរូ ដំណាក់កាលទី១
- ទិដ្ឋភាពរួមនៃផែនការយុទ្ធសាស្ត្រតុលាការ និងអយ្យការគំរូ
- ទិសដៅបន្ត ។

ឯកឧត្តម ស៊ុយ ម៉ុងលាង បានស្នើសុំឱ្យ លោក គង់ ផល្លៈ បញ្ជាក់ឡើងវិញ ពីព្រោះ ឯកឧត្តមយល់ថា ផែនការយុទ្ធសាស្ត្ររបស់តុលាការទាំងបួនមានលក្ខណៈដូចគ្នា ដូច្នេះ តើអាចបញ្ចូលគ្នាតែមួយបានដែរឬទេ ?

លោក គង់ ផល្លៈ បានមានប្រសាសន៍ថា អ្វីដែលលោកលើកមកបង្ហាញនៅពេលនេះ គឺជាការលើកយក យន្តការរួម ប៉ុន្តែតុលាការនីមួយៗអាចមានចំណុចដោយឡែករបស់ខ្លួនបាន ។

ឯកឧត្តមប្រធានបានមានយោបល់ថា បើតាមឯកសារផែនការយុទ្ធសាស្ត្ររបស់តុលាការទាំងបួន គឺមានលក្ខណៈ ប្រហាក់ប្រហែលគ្នាជាច្រើន បានសេចក្តីថា ចំណុចខុសគ្នាមានតែបន្តិចបន្តួចតែប៉ុណ្ណោះ ដូច្នេះយើងគួរដាក់ដោយឡែក ពីគ្នាបែបនេះ ឬក៏យើងបញ្ចូលគ្នាតែមួយ ។ ជាបន្ទាប់ ឯកឧត្តមបានស្នើសុំឱ្យតុលាការក្រុងភ្នំពេញ ធ្វើបទបង្ហាញអំពី ផែនការយុទ្ធសាស្ត្ររបស់ខ្លួន ។

លោកស្រី ចាំង ស៊ីណាត ចៅក្រមសាលាដំបូងក្រុងភ្នំពេញ បានធ្វើបទបង្ហាញពីផែនការយុទ្ធសាស្ត្រ របស់ សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ តាមរយៈការបញ្ចាំងស្លាយ ។

ឯកឧត្តម ស៊ុយ ម៉ុងលាង បានចោទសួរថា តើជាដំបូងយើងត្រូវពិនិត្យពិភាក្សាលើផែនការយុទ្ធសាស្ត្រ របស់តុលាការភ្នំពេញនេះ ថាតើឆ្លើយតបនឹងស្តង់ដារ និងលក្ខណៈវិនិច្ឆ័យហើយឬនៅ ឬក៏រង់ចាំតុលាការទាំងបួនធ្វើបទ បង្ហាញចប់សិន សឹមយើងពិភាក្សាគ្នាជាក្រោយ ។

លោកស្រី Arthi Patel លេខាធិការទី១នៃស្ថានទូតអូស្ត្រាលី បានសួរថា ថវិកាសម្រាប់ផែនការយុទ្ធសាស្ត្រនេះ តើគួរចាប់ផ្តើមនៅពេលណានៅឆ្នាំ២០០៩ ឬក៏ចាំដល់ឆ្នាំ ២០១០ ? ។

ឆ្លើយតបនឹងរឿងនេះ ឯកឧត្តមប្រធានបានមានប្រសាសន៍ថា មានការលើកទឹកចិត្តដល់តុលាការគំរូទាំងបួននេះ ហើយពីខាង AusAid CCJAP & DANIDA ក្នុងការរៀបចំថវិការដើម្បីអនុវត្តលើគម្រោងតុលាការគំរូនេះ ។ ក្រោយពីក្រុមការងារជាន់ខ្ពស់អនុម័តលើផែនការយុទ្ធសាស្ត្រនេះហើយ តុលាការគំរូនីមួយៗត្រូវតែរៀបចំផែនការសកម្មភាព ផ្ទាល់ខ្លួន ហើយដាក់ស្នើសុំ ថវិកាយកមកអនុវត្តទៅក្រុមប្រឹក្សាភិបាល នៃគម្រោង CCJAP III ។

របៀបវារៈបន្ទាប់គឺជាបទបង្ហាញរបស់សាលាដំបូងខេត្តកណ្តាល ដោយលោក អ៊ិន វ៉ាន់វិបុល អនុប្រធានសាលា ដំបូងខេត្តកណ្តាល អំពីផែនការយុទ្ធសាស្ត្ររបស់សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកណ្តាល តាមរយៈឯកសារ ដែលបានចែកជូន ។ មានការស្នើសុំបន្ថែមពាក្យ **ការបិទសំណុំរឿង** " ត្រង់ចំណុច គោលបំណងទី៣.៤ ដែលត្រូវសរសេរ ជាថ្មីថា **ការបិទសំណុំរឿង** ការតំកល់ឯកសារសំណុំរឿង និងឯកសារផ្សេងៗ តាមស្តង់ដារយុទ្ធសាស្ត្រ ទំព័រទី១៣ ។

ឯកឧត្តមប្រធានបានថ្លែងអំណរគុណដល់លោកអនុប្រធានសាលាដំបូងខេត្តកណ្តាល ហើយជាបន្ទាប់ឯកឧត្តមបាន ស្នើសុំឱ្យសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ឡើងធ្វើបទបង្ហាញពីផែនការយុទ្ធសាស្ត្ររបស់ ខ្លួន ។ លោក អាំង មាលតី ប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ ជាអ្នកបង្ហាញជូន ។ មានការស្នើសុំកែសម្រួល ចំណងជើង គោលបំណងទី១.៤.៥ បង្កើន និងអនុវត្តការងារព្យួរទោស ទៅជា " **បង្កើន និងត្រួតពិនិត្យអំពីសាលក្រមដែលសម្រេចព្យួរទោស** " ទំព័រទី១២ ក្នុងឯកសារផែនការយុទ្ធសាស្ត្ររបស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

បន្ទាប់ពីការធ្វើបទបង្ហាញរបស់ប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យចប់ ឯកឧត្តមប្រធានបានពោលសរសើរ ថា តុលាការនេះមានការប្លែកពីយុទ្ធសាស្ត្ររបស់តុលាការផ្សេងទៀត **ត្រង់គោលបំណងទី៣.៥ ស្តីពីអនុវត្តការប្រមូល ប្រាក់ពន្ធចូលថវិការដ្ឋឱ្យមានប្រសិទ្ធិភាពទំព័រទី១៧** ។

លោក ប្លង់ ឆ្លាម ប្រធានសាលាដំបូងខេត្តកំពង់ចាម បានធ្វើបទបង្ហាញពីផែនការយុទ្ធសាស្ត្ររបស់សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពង់ចាម តាមរយៈឯកសារដែលបានចែកជូនដោយគ្មានការកែប្រែអ្វីឡើយ ។

ក្រោយពីចប់បទបង្ហាញរបស់តុលាការទាំងបួនមក ឯកឧត្តមប្រធានបានថ្លែងការកោតសរសើរចំពោះតុលាការ ទាំងអស់ ជាពិសេសនោះចំពោះក្រុមការងាររបស់តុលាការទាំងបួនដែលបានបំពេញការងារយ៉ាងម៉ត់ចត់ ហើយយល់ ច្បាស់ទៅលើទិសដៅទាំងបួន គឺ ៖

1- ការគ្រប់គ្រងរឿងក្តីយោងទៅតាមក្រមនិតីវិធីព្រហ្មទណ្ឌ

2- ការគ្រប់គ្រងរឿងក្តីយោងតាមក្រមនិតិវិធីរដ្ឋប្បវេណី

3- រដ្ឋបាលតុលាការ និងអយ្យការប្រកបដោយប្រសិទ្ធភាព

4- ការគ្រប់គ្រងតុលាការ និងអយ្យការប្រកបដោយប្រសិទ្ធភាព ។

ឯកឧត្តមប្រធានបានបញ្ជាក់ថា ទិសដៅទាំងបួននេះមានលក្ខណៈ ខុសគ្នាតែបន្តិចបន្តួចប៉ុណ្ណោះ ។ ឯកឧត្តមបាន លើកយកចំណុចខុសគ្នានោះមកពិភាក្សាថា តើយើងគួរយករូបមន្តណាមកប្រើៈ

- ចំណុចទី១ នៅក្នុងយុទ្ធសាស្ត្រទាំងបួនមានការស្របគ្នាចំពោះសំណើរចនាសម្ព័ន្ធតុលាការគំរូកម្ពុជាតុលាការជាន់ទាប

- ចំណុចទី២ ឯកឧត្តមប្រធានបានសួរទៅតុលាការទាំងបួនថា តើហេតុអ្វីបានជានៅទិសដៅទីមួយគឺ ការគ្រប់គ្រង រឿងក្តី តុលាការខេត្តកណ្តាល និងតុលាការភ្នំពេញពុំបែងចែកឱ្យដាច់រវាង រឿងក្តីព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ?
- ចំណុចទី៣ តុលាការខេត្តកំពង់ចាម បានបង្ហាញចូលទៅដល់សកម្មភាពរបស់តុលាការ ។ ដែលជាការបញ្ជាក់ ថា មានការយល់ដឹងច្បាស់លាស់អំពីការរៀបចំផែនការនេះ ។
- ឯកឧត្តមប្រធានបានសរសើរជាថ្មី ចំពោះតុលាការខេត្តបន្ទាយមានជ័យដែលមានគំនិតបញ្ចូលការស្វះស្វែងរក ថវិកាជូនរដ្ឋ គឺជារឿងមួយប្រសើរណាស់ ។

ជាមួយគ្នានោះដែរ ឯកឧត្តមប្រធានបានជម្រាបជូនអង្គប្រជុំទាំងមូលថា ឧបនាយករដ្ឋមន្ត្រី សុខ អាន តែងតែ លើកយកតុលាការកាត់ទោសខ្មែរក្រហមជាតុលាការគំរូ សម្រាប់អនុវត្តតាមផងដែរ ។

តំណាងតុលាការខេត្តកណ្តាល បានឆ្លើយតបទៅនឹងចំណុចស្តីពីការគ្រប់គ្រងរឿងក្តីព្រហ្មទណ្ឌ និងរដ្ឋប្បវេណីនៅទំព័រទី៨ ថាការដែលមិនសរសេរចែកជាពីរដាច់ពីគ្នា គឺព្រោះស្ថិតនៅក្នុងចង្កោមរឿងក្តីដូចគ្នា ។ ចំពោះការបង្កើត លេខាធិការដ្ឋាន លោកយល់ថា លេខាធិការដ្ឋាននេះមានតួនាទីសំខាន់ណាស់ ដូចជាតួនាទីជាអ្នកសរសេរប្រតិទិន ការងារ សរសេរផែនការ និងមានតួនាទីជាអ្នកគៀងគររកជំនួយជាដើម ។

ឯកឧត្តមប្រធានបានស្នើសុំឱ្យតុលាការផ្សេងៗទៀតមានមតិយោបល់ជូនអង្គប្រជុំ ។

ប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ បានមានទស្សនៈផ្សេងពីតុលាការខេត្តកណ្តាលថា រឿងក្តីព្រហ្មទណ្ឌ និង រដ្ឋប្បវេណីមានលក្ខណៈមិនដូចគ្នាទេ ប្រសិនបើពិនិត្យមើលលើការអនុវត្តសាលក្រម ដូច្នេះលោកអះអាងថា បើយើង សរសេរបញ្ចូលគ្នា នឹងធ្វើឱ្យបាត់នីតិវិធីរដ្ឋប្បវេណីមួយចំនួន ។ ដោយផ្អែកទៅលើរឿងនេះហើយ ទើបលោកបំបែកចេញពី គ្នា ។ មួយវិញទៀតទាក់ទិននឹងរឿងបង្កើតលេខាធិការដ្ឋាន គឺត្រូវតែមាន ពីព្រោះលោកយល់ថា លេខាធិការដ្ឋាននេះ ជាអ្នកគ្រប់គ្រងរឿងក្តីរបស់ប្រជាពលរដ្ឋបានដោយរលូន និងជាទីពឹងពាក់របស់ប្រជាពលរដ្ឋ ។

ឯកឧត្តម ខៀវ សាម៉េត បានមានប្រសាសន៍ កោតសរសើរចំពោះតុលាការខេត្តកណ្តាល ដែលបានបង្កើត លេខាធិការដ្ឋាន ព្រមទាំងគ្រប់គ្រងបានល្អ និងពោលសរសើរផងដែរ ចំពោះតុលាការបន្ទាយមានជ័យដែលធ្វើបានល្អ ចំពោះការប្រមូលពន្ធជូនរដ្ឋ ជាមួយគ្នានោះដែរ ឯកឧត្តមបានស្នើសុំឱ្យតុលាការផ្សេងៗទៀត គួរតែដាក់បញ្ចូលចំណុច ប្រមូលពន្ធជូនរដ្ឋ នេះ ក្នុងផែនការយុទ្ធសាស្ត្ររបស់ខ្លួន ។

ចំពោះផែនការយុទ្ធសាស្ត្ររបស់តុលាការភ្នំពេញ ឯកឧត្តមសុំឱ្យកែត្រង់គោលបំណងទី១.៥ នៅទំព័រទី១០ យក តាមលំនាំ តុលាការខេត្តកណ្តាល គឺ ៉ការចែកចាយសេចក្តីសំរេច និងបណ្តឹងឧបាស្រ័យឱ្យមានប្រសិទ្ធភាពយុទ្ធសាស្ត្រ " កុំប្រើពាក្យ " បណ្តឹងឧទ្ធរណ៍ " ។

ឯកឧត្តម ជីវ កេង ឯកភាពលើការបង្កើតលេខាធិការដ្ឋាន ពីព្រោះវាអាចជួយខាងផ្នែករដ្ឋបាលបានយ៉ាង ច្រើន ។ សព្វថ្ងៃនេះកំពុងតែយកក្រឡាបញ្ជីធ្វើជាផ្នែករដ្ឋបាលព្រោះមានការខ្វះខាត ។ ឯកឧត្តមបានជម្រាបថា ៖

- ក្រសួងយុត្តិធម៌បានលើកពីការបង្កើតតុលាការរដ្ឋបាល ប៉ុន្តែបារម្ភខ្លាចដាក់ផែនការរួចហើយប៉ុន្តែអត់ចេញ បើដូច្នេះវាជាការបរាជ័យយ៉ាងធំមួយ ។ ហើយឯកឧត្តមបានសួរទៀតថាផែនការដាក់រួចហើយ ត្រីវិស័យក៏ ចង្អុលរួចហើយដែរ តើយើងអាចអនុវត្តផែនការនោះបានឬទេ ?
- ឯកឧត្តមបានលើកពីតុលាការភ្នំពេញថា កាលពី៥ឆ្នាំមុន ថ្ងៃណាក៏មានកាសែតចុះផ្សាយបរិហារអំពី សីលធម៌ របស់ចៅក្រម និងក្រឡាបញ្ជី ដែរ ប៉ុន្តែបន្ទាប់ពីមានការបង្កើតក្រមសីលធម៌របស់ចៅក្រម និងក្រឡាបញ្ជី រួចមកមិនសូវមានកាសែតចុះផ្សាយទៀតទេ ។ ទោះបីជាយ៉ាងណា យើងត្រូវបន្ថែមធនធានមនុស្ស និងពង្រឹង សីលធម៌របស់ចៅក្រម និងក្រឡាបញ្ជី ជាបន្តទៅទៀត ។
- បង្កើនផែនការយុទ្ធសាស្ត្រទាក់ទងទៅនឹងជីវភាពមន្ត្រីតុលាការឱ្យបានសមរម្យ ជាពិសេសចំពោះមន្ត្រីដែល ផ្លាស់ប្តូរទីកន្លែងទៅតាមខេត្តនានា។
- ឯកឧត្តមព្រួយបារម្ភចំពោះថវិកាស្តួចស្តើងមិនគ្រប់គ្រាន់សម្រាប់មន្ត្រីតុលាការក្នុងការអនុវត្តយុទ្ធសាស្ត្រខ្លាច ជាមូលហេតុបណ្តាលឱ្យពួកគាត់មានគំនិតកេងប្រវញ្ចន៍ប្រាក់កាសរបស់ប្រជាពលរដ្ឋនៅលើរឿងក្តី ។
- នៅតាមបណ្តាខេត្តមានរឿងឃាតកម្មជាច្រើន ហើយមន្ត្រីតុលាការខេត្តបានយកសំណុំរឿងមកភ្នំពេញ ដោយ សំអាងថា សំណុំរឿងឯខេត្តមានច្រើនពេកធ្វើមិនទាន់ ហើយក៏មានការគំរាមកំហែងពីជនទុច្ចរិតមកលើ ចៅក្រមរបស់យើងផងដែរ ។
- ថវិកាចំណាយលើផែនការយុទ្ធសាស្ត្រសំរាប់តុលាការ ខាងអង្គការខ្លះនឹងមកជួយលើផែនការសកម្មភាព ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ក៏ឯកឧត្តមនៅតែមានការព្រួយបារម្ភខ្លាចអនុវត្តមិនបាន ។

ឯកឧត្តម ស៊ុយ ម៉ុងលាង បានមានប្រសាសន៍ថា ដោយសារបុព្វហេតុទាំងនេះហើយបានជាយើងត្រូវបង្កើត តុលាការគំរូនេះឡើង គឺដើម្បីរកយុត្តិធម៌ជូនប្រជាពលរដ្ឋ ហើយនឹងដើម្បីឆ្លើយតបនឹងតុលាការទាំងអស់ផងដែរ ។ ដូច្នេះ យើងត្រូវតែប្រឈមមុខរាល់បញ្ហាទាំងអស់ដែលកើតមានឡើង បើយើងមិនប្រឹងប្រែងទេ យើងក៏មិនអាចរកថវិកាដើម្បី អនុវត្តលើផែនការសកម្មភាពរបស់យើងបានដែរ ។ ជាបន្ទាប់ឯកឧត្តមប្រធានបានសួរទៅតុលាការផ្សេងទៀត ថាតើមាន បញ្ហាប្រឈមមុខអ្វីខ្លះចំពោះការអនុវត្តលើយុទ្ធសាស្ត្ររបស់យើងនោះ ។

លោក អាំង មាលតី បានឯកភាពចំពោះឯកឧត្តម ជីវ កេង ដែលចង់បន្ថែមនូវសភាទាំងបី គឺ សភារដ្ឋបាល ត្រូវតែមានច្បាប់រដ្ឋបាល សភាពាណិជ្ជកម្មត្រូវតែមានច្បាប់នីតិវិធីពាណិជ្ជកម្ម និងសភាសង្គមត្រូវតែមាន នីតិវិធីសង្គម ។ ចំណុចប្រឈមមុខ គឺពាក្យអយុត្តិធម៌ ដែលលោកយល់ថាមាននៅពីរកន្លែង ។ កន្លែងទីមួយ គឺ ដំណាក់កាលរដ្ឋបាល ។ ដូចនេះបើសិនជា យើងរៀបចំប្រព័ន្ធរដ្ឋបាលបានល្អ យើងអាចកាត់បន្ថយពាក្យអយុត្តិធម៌បាន មួយចំណែក ។ កន្លែងទីពីរ គឺនៅពេលតុលាការសម្រេចសេចក្តី ។ បញ្ហានេះយើងនឹងខិតខំដោះស្រាយក្រោយ ។ ដើម្បីធ្វើឱ្យរដ្ឋបាលតុលាការមាន តម្លាភាពទៅបាននោះ លុះត្រាតែមានបីចំណុចទៀតគឺ ៖

១-ប្រធានសាលាដំបូងត្រូវមានឆន្ទៈក្នុងការរៀបចំប្រព័ន្ធរដ្ឋបាលឱ្យមានតម្លាភាព

២-ប្រធានតុលាការត្រូវមានសមត្ថភាពរៀបចំ និងដឹកនាំសំដៅទៅលើ ធនធានមនុស្ស មានជីវភាពរស់នៅ សមរម្យ និងមានសីលធម៌

៣-មធ្យោបាយធ្វើដំណើរក្នុងពេលបំពេញការងារ ត្រូវមានដូចជា សម្ភារៈសម្រាប់ធ្វើដំណើរ និងថវិកាផងដែរ ។ សួរថា តើចំណុចនេះយើងបានដោះស្រាយរួចហើយឬនៅ ? បើដោះស្រាយមិនចេញទេ គឺវានៅតែជាបញ្ហាប្រឈមមុខ ដដែលៗ ។

មានបញ្ហាជាច្រើនដូចជារឿងក្តីមួយចំនួន ដែលប្រជាពលរដ្ឋតែងតែរអ៊ូរថា រឿងក្តីរបស់គាត់មានការយឺតយ៉ាវជា ដើម បញ្ហាគ្មានមេធាវីចូលរួម បញ្ហាបញ្ជូនដីកាកោះ ដល់ពេលបើកសវនាការ ដំណឹងមិនបានទៅដល់ដៃ ជាហេតុធ្វើឱ្យ មានការយឺរយ៉ាវដល់ស្ថាប័នតុលាការ ។ ចំណែក បញ្ហាប្រឈមមុខដ៏ទៃទៀតមានដូចជា អ្នកជំនាញមិនបានចូលរួម នេះជាចំណុចដែលធ្វើឱ្យកកស្ទះដល់តុលាការ ។

ចំណុចអយុត្តិធម៌ពាក់ព័ន្ធចំនួន៣ចំណុច:

១-ចៅក្រមខ្វះសមត្ថភាព

២-អំពីឯករាជ្យរបស់ចៅក្រម ទាក់ទងទៅនឹងជីវភាពចៅក្រម ដូចឯកឧត្តម ជីវ កេង បានលើកឡើងអំពីការ គំរាមកំហែងទៅលើចៅក្រម គឺស្ថានភាពសន្តិសុខរបស់ចៅក្រម បើមានការគំរាមកំហែងទៅលើចៅក្រម បែប នេះថាតើចៅក្រមមានឯករាជ្យភាពយ៉ាងដូចម្តេច ?

៣-អំពីសីលធម៌របស់ចៅក្រមទំនាក់ទំនង និងក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ចំពោះឧបសគ្គមាន:

១-ការផ្តល់ឯកសារភ័ន្តច្រឡំ ដូចជាមន្ត្រីមូលដ្ឋានផ្តល់ព័ត៌មានមកចៅក្រមច្រឡំពាក់ព័ន្ធរឿងដីធ្លី ដូច្នេះដល់ពេល កាត់ក្តីតុលាការក៏កាត់ទៅតាមឯកសារខុសនោះ ប៉ុន្តែប្រជាពលរដ្ឋបែរជាស្រែក ថា អយុត្តិធម៌ ទៅវិញ

២-ការរំលោភទៅលើអំណាច និងភារៈកិច្ចរបស់តុលាការ " សូមមិនបកស្រាយ "

៣-ការបំភ័យទៅលើសន្តិសុខផ្ទាល់ខ្លួនរបស់ចៅក្រម

៤-ការមើលបំណាំគ្នារបស់ចៅក្រម ដោយសារឃើញម្នាក់ធ្វើខុសហើយមិនឃើញដាក់ទោស ។

លោក Michael Engquist, Senior Programme Officer,Danida បានថ្លែងអំណរគុណចំពោះការខិតខំ ប្រឹងប្រែងយ៉ាងខ្លាំងរបស់តុលាការទាំង៤ និងសូមធានាដល់ឯកឧត្តម លោកជំទាវ លោកស្រី ចំពោះការគាំទ្រដល់កំណែ ទម្រង់ច្បាប់ និងតុលាការ ហើយលោកជឿជាក់ថា រដ្ឋាភិបាលនឹងបំពេញថវិកាបន្ថែមទៅលើតម្រូវការនេះ ។

ឯកឧត្តម ច័ន្ទ មនោ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌ បានមានប្រសាសន៍ ថា ដំណើរការរៀបចំតុលាការគំរូ បានឈានចូលមកដល់ជំហ៊ានទី២ហើយ គឺជាដំណាក់កាលអនុវត្ត ។ ដើម្បីអនុវត្តទៅបាន នោះគឺទាល់តែមានថវិកា ។ ជាមួយគ្នានោះដែរ លោកបានជម្រាបជូនថា តុលាការទាំងបួនបានអនុវត្តការងាររួមគ្នា ហើយ ខាងក្រសួងយុត្តិធម៌ក៏ទទួលបាននូវតារាងតួលេខពីតុលាការទាំងបួនហើយដែរ ។ សរុបទាំងអស់គឺ បួនពាន់លានរៀល ។ ជាដំបូងឯកឧត្តមបានទំនាក់ទំនងជាមួយក្រសួងហិរញ្ញវត្ថុ ហើយសួរថាតើអាចទទួលយកបាន ទេ ចំពោះថវិកាខាងលើនេះ ? ក្រសួងហិរញ្ញវត្ថុបានឆ្លើយថា អាចជួយយើងបានដោយត្រូវបំពេញឯកសារឱ្យបានគ្រប់គ្រាន់បញ្ជាក់ឱ្យបានច្បាស់ថា មាន ម្ចាស់ជំនួយណាជួយដល់គម្រោងនោះជាដើម ។ លោកនឹងធ្វើការជាបន្ត ក្រោយពេលដែលទទួលបានផែនការសកម្មភាព របស់តុលាការទាំងបួន ។ ក្នុងការធ្វើការស្នើសុំថវិកានេះ គឺលោក គុង ពារ ជាអ្នកអនុវត្តផ្នែកបច្ចេកទេស ។ ប៉ុន្តែលោកបានដាស់តឿនសូមឱ្យយកថវិកាមកប្រើប្រាស់ឱ្យបានត្រឹមត្រូវ ហើយលោកបញ្ជាក់ថែមទៀតថា ការស្នើសុំមិន មែនសុទ្ធតែបានគ្រប់សំណើទាំងស្រុងនោះទេ ដូច្នេះសល់ប៉ុន្មានលោកសង្ឃឹមថា ខាងម្ចាស់ជំនួយផ្សេងៗនឹងជួយយើង ។

ឯកឧត្តមប្រធានអង្គប្រជុំមានសង្ឃឹមច្រើនចំពោះដៃគូអភិវឌ្ឍន៍ថា នឹងជួយ ។

ឯកឧត្តម សួង លាងហៃ អគ្គលេខាធិការរងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានស្នើសុំឱ្យតុលាការទាំង បួនពិនិត្យកែសម្រួលឡើងវិញនូវផែនការយុទ្ធសាស្ត្ររៀងៗខ្លួន ដោយបញ្ចូលនូវចំណុចទាំងឡាយ ដែលលើកឡើងនៅក្នុង អង្គប្រជុំ ដែលផែនការយុទ្ធសាស្ត្រនីមួយៗ នោះមិនបានសរសេរបញ្ចូល ព្រោះថា ចំណុចខ្វះខាតទាំងអស់នោះសុទ្ធតែត្រូវ បានតុលាការគំរូទាំងបួនទទួលស្គាល់ និងឯកភាព ។

ឯកឧត្តម ស៊ុយ ម៉ុងលាង បានមានប្រសាសន៍បញ្ជាក់តាមអនុសាសន៍ របស់ចៅក្រមតុលាការក្រុងភ្នំពេញថា ការរៀបចំផែនការយុទ្ធសាស្ត្រ គ្រាន់តែជាការរៀបចំយុទ្ធសាស្ត្រសំខាន់ៗ ចំពោះបញ្ហាលំអិតរបស់តុលាការមិនបានដាក់នៅ ក្នុងផែនការយុទ្ធសាស្ត្រនោះទេ ហើយឯកឧត្តមបានយល់ស្របចំពោះផែនការយុទ្ធសាស្ត្ររបស់តុលាការបន្ទាយមានជ័យ ដែលបានលើកឡើងពីការខិតខំប្រមូលពន្ធជូនរដ្ឋ ។

ឯកឧត្តមប្រធានបានថ្លែងអំណរគុណសារជាថ្មី ចំពោះអ្នកចូលរួមទាំងអស់ និងប្រកាសថា ផែនការយុទ្ធសាស្ត្រ របស់តុលាការគំរូទាំងបួនត្រូវបានអនុម័ត ដោយក្រុមការងារជាន់ខ្ពស់ សម្រាប់គម្រោងតុលាការគំរូ គ្រាន់តែមានការកែ សម្រួលបំពេញបន្ថែម បន្តិចបន្តួចទៅតាមការលើក ឡើងរបស់អង្គប្រជុំ ។

អង្គប្រជុំពិភាក្សាបានបញ្ចប់នៅវេលាម៉ោង០៦ និង៥៥នាទីល្ងាចនាថ្ងៃដដែល ។

**បានឃើញ និងឯកភាព**

**ប្រធានអង្គប្រជុំ** **អ្នកធ្វើរបាយការណ៍**

**ស៊ុយ ម៉ុងលាង** **សេង វ៉ាន់ដា** **ស៊ុន សិរីវុធ**

បញ្ជីឈ្មោះសមាសភាពចូលរួមក្នុងកិច្ចប្រជុំពិភាក្សា

នាថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៩

០១-ឯកឧត្តម ស៊ុយ ម៉ុងលាង អគ្គលេខាធិការ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ( កកចយ )

០២-ឯកឧត្តម សួង លាងហៃ អគ្គលេខាធិការរង ( កកចយ )

០៣-ឯកឧត្តម ប៉ែន ប៊ុនឈា អគ្គលេខាធិការរង ( កកចយ )

០៤- ឯកឧត្តម បួន សុមុនី អគ្គលេខាធិការរង ( កកចយ )

០៥- ឯកឧត្តម ផៃ សុខខេង ប្រធានផ្នែកកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ( កកចយ )

០៦- ឯកឧត្តម ផៃ លី អនុប្រធានផ្នែកកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ( កកចយ )

០៧- លោក ជឹង ផេងស្រួយ ប្រធានផ្នែកបណ្ណសារ និងព័ត៌មានវិទ្យា ( កកចយ )

០៨- លោកស្រី ស្រី ប៊ុណ្ណារ័ត្ន អនុប្រធានផ្នែកបណ្ណ័សារ និងព័ត៌មានវិទ្យា ( កកចយ )
០៩- លោក ឆុង ហួត ប្រធានផ្នែកកំណែទម្រង់ច្បាប់ ( កកចយ )
១០-លោក គង់ ផល្ល: អនុប្រធានផ្នែកកំណែទម្រង់ច្បាប់ ( កកចយ )
១១-លោក ឃ្លោក ដារ៉ា ប្រធានផ្នែកលើកកំពស់សិទ្ធិមនុស្ស និងមជ្ឈត្តកម្ម ( កកចយ )
១២-លោក គួយ សៅ អនុប្រធានផ្នែកលើកកំពស់សិទ្ធិមនុស្ស និងមជ្ឈត្តកម្ម ( កកចយ )
១៣-លោកស្រី ហួង សុកុល អនុប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ
១៤-លោកស្រី យិន កក្កដា ប្រធានការិយាល័យ ( កកចយ )
១៥-លោកស្រី ឈូក សារ៉ុម ប្រធានការិយាល័យ ( កកចយ )
១៦-លោកស្រី សេង វ៉ាន់ដា ប្រធានការិយាល័យ ( កកចយ )
១៧-លោក ស៊ុន សិរីវុធ ជំនួយការរដ្ឋបាល និងហិរញ្ញវត្ថុ ( កកចយ )
១៨-កញ្ញា ផាន់ ពីសីនលក្ខណ៏ មន្ត្រី ( កកចយ )
១៩-លោក ហូរ ភត្រា មន្ត្រី ( កកចយ )
២០-លោក សួន វិរ: មន្ត្រី ( កកចយ )
២១-ឯកឧត្តម ខៀវ សាម៉េត ប្រធានតុលាការខេត្តកណ្តាល
២២-កញ្ញា ជា សុភី មន្ត្រី ( កកចយ )
២៣-លោក កើត វណ្ណារ៉េត ព្រះរាជអាជ្ញារងអយ្យការខេត្តកណ្តាល
២៤-លោក ឡុង នូរ៉ា ក្រឡាបញ្ជីនាយកសាលាដំបូងខេត្តកណ្តាល
២៥-លោក គី ប៊ុណ្ណារ៉ា ជំនួសលោក អ៊ុក គឹមសិទ្ធ ព្រះរាជអាជ្ញាអមតុលាការខេត្តកណ្តាល
២៦-ឯកឧត្តម ប៊ុន ហ៊ុន អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌
២៧-លោក សុខ កល្យាណ ព្រះរាជអាជ្ញារងអយ្យការក្រុងភ្នំពេញ
២៨-ឯកឧត្តម ជីវ កេង ប្រធានតុលាការក្រុងភ្នំពេញ
២៩-ឯកឧត្តម ទី ណេង អនុប្រធានសាលាឧទ្ធរណ៍
៣០-ឯកឧត្តម ចន្ទ័ មនោ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌
៣១-លោក គុង ពារ អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌
៣២-លោក ប្លង់ ឆ្លាម ប្រធានសាលាដំបូងខេត្តកំពង់ចាម
៣៣-លោក ឈុន ង៉ន ព្រះរាជអាជ្ញារងអយ្យការខេត្តកំពង់ចាម
៣៤-លោក អំ សំអាត ក្រឡាបញ្ជីនាយកអយ្យាការខេត្តកំពង់ចាម
៣៥-លោក អាំង មាលតី ប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ
៣៦-លោក គឹម សំលេង ព្រះរាជអាជ្ញារងអយ្យការខេត្តបន្ទាយមានជ័យ
៣៧-លោក លឹម ស៊ីណាត ក្រឡាបញ្ជីនាយកសាលាដំបូងខេត្តបន្ទាយមានជ័យ
៣៨-ឯកឧត្តម ហេង ជី ទីប្រឹក្សាជាន់ខ្ពស់តុលាការគំរូ
៣៩-លោក កែ សាខន អនុប្រធានសាលាដំបូងក្រុងភ្នំពេញ
៤០-លោកស្រី ចាំង ស៊ីណាត ចៅក្រមសាលាដំបូងក្រុងភ្នំពេញ

៤១-លោក ហួយ សេរីវឌ្ឍនៈពិសិដ្ឋ ជំនួយការក្រុមការងារតុលាការគំរូ

៤២-លោក ជុំ ណារ៉ាន់ គណនេយ្យករសាលាដំបូងខេត្តកំពង់ចាម

៤៣-កញ្ញា ហេង បូភា ក្រឡាបញ្ជីនាយកសាលាដំបូងក្រុងភ្នំពេញ

៤៤-លោក អិន វ៉ានវិបុល អនុប្រធានសាលាដំបូងខេត្តកណ្តាល

៤៥-ំស។ោរតហិ Patel,First Secretary (AusAid)

៤៦-ំរ។ូាន Sokha, Project Officer Of MOJ, CCJAP

៤៧- Mr.Phok Phira, Jica

៤៨-ំរ។ភតេរ May, Court Advisor (CCJAP)

៤៩- Mr.Ben Schultz, CCJAPIII

៥០- Mr.Chor Siek Veng, Project Officer

៥១-ំរ។ំិចហាលេ Engquist, Senior Programme Officer (Danida)

៥២-ំរ។ះាខ Howlett, Legal Advisor(EWMI)